# ចារឹកលើវត្ថុលោហៈក្នុងរាជ្យព្រះបាទជ័យវម្ម័ទី៧ (ភាគ១)

នៅក្នុងរាជ្យព្រះបាទជ័យវម្ម័ទី៧ យើងសង្កេតឃើញថា សិលាចារឹកភាគច្រើន ច្រើនតែចារជាភាសាសំស្ក្រឹត។ ចំណែកឯសិលាចារឹកភាសាខ្មែរវិញ ពុំចារឹកជាអត្ថបទវែងៗដូចសម័យមុនៗឡើយ។ ភាគច្រើន គឺជាសិលាចារឹកខ្លីៗ ចារនៅលើមេទ្វារប្រាសាទ ដើម្បីប្រាប់ព័ត៌មានអំពីព្រះនាមទេពដែលតម្កល់ក្នុងប្រាសាទ និងម្ចាស់ទានដែលប្រតិស្ឋានទេពនោះជាដើម។[១] ចំពោះសិលាចារឹកភាសាខ្មែរដែលវែងជាងគេនៅក្នុងរជ្ជកាលនោះ គឺសិលាចារឹករកឃើញនៅប្រាសាទបន្ទាយឆ្មារ K.២២៧ ដែលចារឹកអំពីការប្រតិស្ឋានបដិមាតំណាងឱ្យព្រះអង្គម្ចាស់ស្រិន្ទ្រកុមារ នៅគ្រឹហារត្ន[២]កណ្តាល និងមន្ត្រីបួននាក់ទៀតដែលមានឋានន្តរនាមជា «អ្នកសញ្ជក» នៅទិសតូចទាំងបួន ដែលអ្នកទាំងបួនបានពលីជីវិតក្នុងទេសកាលពីរផ្សេងគ្នា។

ក្រៅពីសិលាចារឹកខ្លីៗនៅលើមេទ្វារប្រាសាទ ក៏សង្កេតឃើញមានចារឹកខ្លីៗនៅលើវត្ថុប្រើប្រាស់ផ្សេងៗដែលសាងអំពីលោហធាតុដូចជាមាស ប្រាក់ និងសំរិទ្ធជាដើម។ អត្ថបទនេះ នឹងលើកយកចារឹកខ្លីៗទាំងនោះមកពិនិត្យមើល ដោយប្រែសម្រួលមកជាភាសាខ្មែរទំនើប ព្រមទាំងពិភាក្សាអំណានមួយចំនួនដែលមិនច្បាស់លាស់ នៅក្នុងការសិក្សាកន្លងមក។

## ១- ចារឹក K. ១០៥៣

ចារឹកនេះ ចារឹកលើវត្ថុសាងអំពីសំរិទ្ធ ដែលគេសន្និដ្ឋានថាជាជើងទម្រកញ្ចក់ (support de miroir) រកឃើញនៅស្ថានីយ៍បុរាណវិទ្យាលេខ១១ ស្ថិតនៅបរិវេណក្រុងព្រះរថដងស្រីមហាពោធិ៍ ឃុំគោកប៉ិប ស្រុកស្រីមហោសថ (ព័ត៌មានដើមថា ស្រុកស្រីមហាពោធិ៍) ខេត្ត-

---

[១] ឆោម គន្ធា, ២០២០។

[២] ពាក្យបុរាណសរសេរថា «គ្រឹហរត្ន» សំដៅដល់តួប៉មប្រាសាទ។ ថ្មីៗនេះ លោកបណ្ឌិត អាំង ជូលាន បានស្នើពាក្យ «ក្តី» ដែលមានវត្តមានប្រើប្រាស់តាំងពីបុរាណ សម្រាប់ហៅជំនួសពាក្យខ្មែរហៅតាមបារាំង «តួប៉ម» (tour)។ សូមអានបន្ថែមៈ អាំង ជូលាន, ២០២១។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ប្រាចីនបុរី ប្រទេសថៃ។ ទីតាំងនេះ គឺជាអពេត្យសាលា ឬមន្ទីរពេទ្យ នៅក្នុងរជ្ជកាលព្រះបាទជ័យវម៌្មទេវទី៧។ បច្ចុប្បន្ន វត្ថុនេះរក្សាទុកនៅក្នុងសារមន្ទីរខេត្តប្រាចីនបុរីប្រទេសថៃ។

ចារឹកនេះ សិក្សាដំបូងដោយលោក ហ្សង់ ប៊័រស៊េលីយេ៉រ (Jean Boisselier) នៅក្នុងឆ្នាំ ១៩៧២ ក្នុងអត្ថបទស្ដីអំពី កិច្ចបេកសកម្មបុរាណវិទ្យាបារាំងនៅប្រទេសថៃ។[៣] បន្ទាប់មក នៅប្រទេសថៃ ក៏មានការសិក្សាអំពីចារឹកនេះដូចគ្នា និងមាននៅលើគេហទំព័ររបស់មជ្ឈមណ្ឌលជាតិពន្ធុវិទ្យាសិរិនថនផងដែរ។[៤] បន្ថែមពីនេះ នៅលើហ្វេសប៊ុករបស់លោកសាស្ត្រាចារ្យ កង្វល់ គជ្ជិមា ក៏ឃើញមានសំណេរអំណានថ្មីផងដែរ។[៥]

លោក ហ្សង់ ប៊័រស៊េលីយេ៉រ បានអានកាលបរិច្ឆេទនៅលើចារឹកនេះ ជាពីរជម្រើស គឺមហាសករាជឆ្នាំ ១១១៤ ឬ ១១១៥ ដោយលោកពន្យល់ថា សញ្ញាតួលេខ ៤ និងលេខ ៥ មានរូបរាងប្រហាក់ប្រហែលគ្នា។ ចំណែកអំណាននៅក្នុងអត្ថបទរបស់មជ្ឈមណ្ឌលជាតិពន្ធុវិទ្យាសិរិនថន អានជាមហាសករាជឆ្នាំ ១១១៥។ ដោយសារនៅក្នុងរជ្ជកាលព្រះបាទជ័យវម៌្មទេវទី៧ កម្រមានអត្ថបទភាសាខ្មែរបុរាណនិងប្រើប្រាស់សញ្ញាលេខ វាពិតជាមានការលំបាកខ្វះ សម្រាប់ញែកសញ្ញាតួលេខទាំងពីរនេះ។ ប៉ុន្តែប្រសិនបើយើង ពិនិត្យទម្រង់តួលេខលើចារឹកនេះ ជាមួយតួលេខសម័យមុនៗ នោះយើងនឹងឃើញច្បាស់ប្រាកដថាជាតួលេខ៥។ ដូច្នេះ កាលបរិច្ឆេទលើចារឹកនេះ ត្រូវនឹងគ្រិស្តសករាជឆ្នាំ ១១៩៣ - ១១៩៤។

ចារឹកនេះ នៅមានបញ្ហាអំណានត្រង់ចន្លោះព្រះនាមព្រះបាទជ័យវម៌្មទេវទី៧និងពាក្យ «ត»។ ត្រង់ចំណុចនេះ លោក ប៊័រស៊េលីយេ៉រ ពុំបានដាក់អំណានជាអក្សរសំណាងឡាតាំងនឡើយ។ លោកបានគូសទម្រង់តួអក្សរខ្មែរបុរាណ ដាក់ក្នុងអំណានរបស់លោកយ៉ាងដូច្នេះ «ꟷ»។ នៅក្នុងឯកសារមជ្ឈមណ្ឌលសិរិនថន បានអានអំណានតួអក្សរនេះថាជាអក្សរ «ទ»។ ចំណែកឯលោកសាស្ត្រាចារ្យ កង្វល់ គជ្ជិមា បានស្នើអំណានឃ្លានេះថា [...]

[៣] សូមអានបន្ថែម៖ Boisselier, 1972។

[៤] សូមអានបន្ថែម៖ https://db.sac.or.th/inscriptions/inscribe/detail/447 ។

[៥] សូមអានបន្ថែម៖ https://bit.ly/3PHGS86 ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

វ្រះបាទកម្រតេងអញត្រីជយវម៌្ម៧តវ្រះអារោគ្យសាល[...]។ ត្រង់ចំណុចឃ្លានេះ ចារឹកខ្លីនេះទំនងជាអ្នកចារមានបញ្ហាភ្លេចតួអក្សរ ដែលនាំឱ្យផ្ងាយកាន់ប្រឡំអំណាន។ ឃ្លាដែលត្រឹមត្រូវ គួរតែជា [...] វ្រះបាទកម្រតេងអញត្រីជយវម៌្ម(ទេវ)តវ្រះអារោគ្យសាល[...] ដូចដែលឃើញមានលើចារឹកលោហៈផ្សេងៗទៀតរបស់ទ្រង់។ ដូច្នេះ អ្នកចារចារឹកនេះ បានភ្លេចតួស្រៈ «ៀ» និងអក្សរ «វ»។ ដូចគ្នាដែរ ចំពោះពាក្យ «អារោគ្យសាល» តួ «សា» ហាក់មិនច្បាស់លាស់។ ជាទូទៅ អក្ខរាវិរុទ្ធត្រឹមត្រូវរបស់ពាក្យនេះ តាមភាសាសំស្ក្រឹត គឺ «អារោគ្យគាល»។ អ្នកចារ ហាក់មានភាពមិនច្បាស់លាស់ចំពោះចំណារនេះ។ បើពិនិត្យតាមទំហំតួអក្សរ គួរតែជារូបរាងរបស់ «គា» ប៉ុន្តែបែរជាពុំមានគំនូរគ្រេនៅខាងឆ្វេង និងមានរូបរាងចេញជា «សា» ទៅវិញ។ នៅលើវត្ថុលោហៈមួយនេះ ក៏ឃើញមានចារតួអក្សរ «ឃ» ធំមួយដែលទំនងជាអ្នកចារនោះ សាកដែកចារ។ ចំណុចទាំងនេះ បង្ហាញឱ្យឃើញថាអ្នកចារឹកនេះ ហាក់មិនយកចិត្តទុកដាក់ខ្លាំងទៅលើអក្ខរាវិរុទ្ធ ដែលនាំឱ្យភ្លេចតួអក្សរនិងចារអក្សរខ្វះមិនច្បាស់លាស់។

ចារឹកខ្លីនេះ ចារអំពីវត្ថុដែលជាជើងទម្រកញ្ចក់(?)នេះ គឺព្រះរាជតង្វាយរបស់ព្រះបាទជ័យវម៌្មទេវទី៧ ថ្វាយចំពោះព្រះអារោគ្យសាលា ឬមន្ទីរពេទ្យ នៅអាវធ្យបូរ។ ស្ថាននាម «អាវធ្យបូរ» មានបង្ហាញក្នុងសិលាចារឹកមួយចំនួនដូចជា៖ សិលាចារឹកប្រាសាទព្រះវិហារ (K.៣៨០) ដែលប្រាប់ថាទីនោះគឺជាស្រុក(=ភូមិ)មួយ (ស្រុកិអវធ្យបុរ) ដែលមានព្រះគម្តែងអញស្រីរាជបតិវម៌្ម ជាម្ចាស់ ។

ស្ថាននាមមួយនេះ គួរតែត្រូវនឹងទីតាំងដែលរកឃើញវត្ថុលោហៈមួយនេះ។ ប៉ុន្តែនៅទីនោះក៏មាន ចារឹកលើលោហៈផ្សេងទៀត ក្នុងសម័យតែមួយនោះ បញ្ជាក់ថាព្រះបាទជ័យវម៌្មទេវទី៧ ថ្វាយចំពោះព្រះអារោគ្យសាលានៅឯសំរោក ផងដែរ។ ព័ត៌មានលើចារឹកនោះ បានបង្កើតជាចម្ងល់ថា ទីតាំងស្ថានីយ៍បុរាណវិទ្យាលេខ១១ ស្ថិតនៅបរិវេណក្រុងព្រះរថ នោះ ជា «អាវធ្យបូរ» ឬ «សំរោក»។ ទីតាំងទាំងពីរនេះ ទំនងជាមិននៅឆ្ងាយពីគ្នា ឬមានទីតាំងណាមួយនៅចំណុះឱ្យទីតាំងមួយទៀត ដូចមានឃើញមានភស្តុតាងតាំង

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ពីសម័យមុនអង្គរមកម្ល៉េះ។ យ៉ាងណាក្តី ចម្ងល់នេះ គួរតែមានការសិក្សាស្វែងយល់ឱ្យបាន ច្បាស់លាស់ តាមរយៈភស្តុតាងនានា។

## អត្ថបទជាអក្សរខ្មែរទំនើប

១- ៙១១១៥គកវ្រះជំនូនវ្រះបាទកម្រតេងអញត្រិជយវម៌្ម[◌េ]ទ[វ]តវ្រះអារោគ្យសា

២- លនាអាវធ្យបុរ ៚

## អត្ថបទសម្រួលជាភាសាខ្មែរទំនើប

មហាសករាជឆ្នាំ១១១៥ (គ្រិស្តសករាជឆ្នាំ១១៩៣-១១៩៤) ព្រះរាជជំនូននៃព្រះបាទកម្តែងអញស្រីជ័យវម៌្មទេវ(ទី៧ ថ្វាយ)ចំពោះព្រះអារោគ្យសាលា នៅឯអាវធ្យបូរ។

### ឯកសារយោង


ធោម គន្ធា

(២០២០). សិលាចារឹកលើមេទ្វារតាមប្រាសាទក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧. មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ នៃអាជ្ញាធរជាតិអប្សរា។

អាំង ជូនលាន

(២០២១). ក្តី. ក្នុង «ព្រឹត្តិបត្រសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ»។

Boisselier, J.

(1972). Travaux de la mission archéologique française en Thaïlande (juillet-novembre 1966). Arts asiatiques, 25, 27-90.


KHMER CIVILIZATION

# បញ្ជីរូបភាព



ទូតាំងបង្ហាញចារឹក K. ១០៥៣ (រូបថត៖ Prachin Buri National Museum)



រូបលេខ១៖ លោហៈជើងទម្រកញ្ចក់មានចារឹក K. ១០៥៣

(រូបថត៖ Prachin Buri National Museum)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



**Numération du vieux khmer**

| Dates (śaka) | VI$^e$-VII$^e$ | VIII$^e$ | IX$^e$ | X$^e$ | XI$^e$ | XII$^e$ | |
|---|---|---|---|---|---|---|---|
| 0 | | - | | | | | ០ |
| 1/2 | | - | - | - | - | - | - |
| 1 | | | | | | | ១ |
| 2 | | | | | | | ២ |
| 3 | | | | | | | ៣ |
| 4 | | | | | | | ៤ |
| 5 | | | | | | | ៥ |
| 6 | | | | | | | ៦ |
| 7 | | | | | | - | ៧ |
| 8 | | | | | | | ៨ |
| 9 | | | | | | | ៩ |
| 10 | | | | | | | ១០ |
| 20 | | | | | | | ២០ |
| 40 | | - | | | | - | ៤០ |
| 60 | | - | | | | - | ៦០ |
| 80 | | - | | | - | - | ៨០ |
| 100 | | - | | | - | - | ១០០ |
| 120 | | - | - | - | - | - | ១២០ |
| 200 | | - | | | - | - | ២០០ |
| 300 | - | - | | | - | - | ៣០០ |

តារាងសញ្ញាលេខខ្មែរបុរាណ

រូបថត៖ Dominique Soutif, Julia Estève និង Chea Socheat (APSARA)

អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយៈ ហ៊ុន ឈុនតេង